**សាលាដំបូងខេត្តកំពង់ស្ពឺ**

-សំណុំរឿងរដ្ឋប្បវេណីលេខ: ២២៧
ចុះថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ២០២២
-សាលក្រមរដ្ឋប្បវេណីលេខ:១៤៦ "ខ"
ចុះថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ២០២២

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលក្រម**
**ក្នុងនាមប្រជារាស្ត្រខ្មែរ**
**សាលាដំបូងខេត្តកំពង់ស្ពឺ**

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់
នៅថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២២។

**ចៅក្រម**

លោក [redacted] ចៅក្រមសាលាដំបូងខេត្តកំពង់ស្ពឺ

**ក្រឡាបញ្ជី**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកំពង់ស្ពឺ

–សហដើមចោទ:

១.ឈ្មោះ [redacted] កុលភ៉ាណេ ភេទប្រុស អាយុ ៤៨ឆ្នាំ ជនជាតិខ្មែរ មានអាសយដ្ឋាននៅ [redacted]

២.ឈ្មោះ [redacted] បូភ៉ា ភេទប្រុស អាយុ ៤១ឆ្នាំ ជនជាតិខ្មែរ មានអាសយដ្ឋាននៅភូមិ [redacted]

អ្នកតំណាងដោយអាណត្តិមេធាវី [redacted]។

–សហចុងចម្លើយឈ្មោះ [redacted] បូរ៉ាក់ ភេទប្រុស អាយុ ៥៣ឆ្នាំ ជនជាតិខ្មែរ និងប្រពន្ធឈ្មោះ [redacted] យឹម ឬ [redacted] យឹម ភេទស្រី អាយុ ៣៩ឆ្នាំ មានអាសយដ្ឋានបច្ចុប្បន្ន [redacted]។

**<u>អង្គហេតុ និងចំណុចវិវាទ</u>**

**ក.ខ្លឹមសារនៃសាលក្រមដែលសហដើមចោទទាមទារឲ្យតុលាការចេញ:**

១.បង្គាប់ឲ្យសហចុងចម្លើយឈ្មោះ [redacted] បូរ៉ាក់ និងប្រពន្ធឈ្មោះ [redacted] យឹម ឬ [redacted] យឹម សងបំណុលចំនួន ៦៦៦.៦០០$ (ប្រាំមួយសែនប្រាំមួយម៉ឺនប្រាំមួយពាន់ប្រាំមួយរយដុល្លារអាមេរិក) មកសហដើមចោទឈ្មោះ [redacted] កុលភ៉ាណេ និងឈ្មោះ [redacted] បូភ៉ា គ្រប់ចំនួន។

២.បង្គាប់ឲ្យសហចុងចម្លើយឈ្មោះ [redacted] បូរ៉ាក់ និងប្រពន្ធឈ្មោះ [redacted] យឹម ឬ [redacted] យឹម បង់ប្រាក់ជម្ងឺចិត្ត ខាតបង់ពេលវេលា និងសេវាកម្មច្បាប់ចំនួន ៥០.០០០$(ប្រាំម៉ឺនដុល្លារអាមេរិក) មកសហដើមចោទឈ្មោះ [redacted] កុលភ៉ាណេ និងឈ្មោះ [redacted] បូភ៉ា គ្រប់ចំនួន។

៣.ប្រសិនបើសហចុងចម្លើយឈ្មោះ [redacted] បូរ៉ាក់ និងប្រពន្ធឈ្មោះ [redacted] យឹម ឬ [redacted] យឹម រឹងរូះមិនព្រមសងបំណុល សុំទាមទាររឹបអូសទ្រព្យសម្បត្តិ(ដី និងផ្ទះ) លក់ឡាយឡុងសងបំណុលមកឲ្យសហដើមចោទឈ្មោះ [redacted] កុលភ៉ាណេ និងឈ្មោះ [redacted] បូភ៉ា គ្រប់ចំនួន និងសុំអនុវត្តសាលក្រមជាបណ្ដោះអាសន្ន។

៤.សហចុងចម្លើយជាអ្នករ៉ាប់រងប្រាក់ប្រដាប់ក្ដី។

## ខ.ដំណើររឿងក្ដី និងចំណុចវិវាទ

ខ.១.ការសង្ខេបរឿងក្ដី: ក្នុងរឿងក្ដីនេះ ដើមចោទប្ដឹងឲ្យសហចុងចម្លើយសងបំណុលចំនួន ៦៦៦.៦០០$ (ប្រាំមួយសែនប្រាំមួយម៉ឺនប្រាំមួយពាន់ប្រាំមួយរយដុល្លារអាមេរិក) ដោយសារកាលពីអំឡុងឆ្នាំ២០១០ សហចុងចម្លើយឈ្មោះ [redacted] បូរ៉ាក់ និងឈ្មោះ [redacted] ឃីម ឬ [redacted] ឃីម បានមកលួងលោងសហដើមចោទ និងប្រជាពលរដ្ឋជាច្រើនអ្នកទៀតឲ្យលេងតុងទីនជាមួយ ដោយក្នុងម្នាក់លេងជាច្រើនក្បាល ហើយការលេងតុងទីននេះដែរ សហចុងចម្លើយជាមេតុងទីនបានដេញមុនគេដោយប្រមូលប្រាក់អស់។ នៅពេលដែលសហដើមចោទដេញយកវិញ ស្រាប់តែសហចុងចម្លើយមិនបានបើកប្រាក់ឲ្យសហដើមចោទ។ ប៉ុន្តែរហូតមកដល់ពេលនេះសហចុងចម្លើយបានរត់គេចខ្លួនមិនទាន់ទូទាត់សងបំណុលជាមួយសហដើមចោទឡើយ។

**ខ.២.ចំណុចវិវាទ ៖ គ្មានចំណុចវិវាទ។**

**ខ.៣.ការអះអាងរបស់គូភាគី**

**-ការអះអាងរបស់សហដើមចោទ៖** កាលពីអំឡុងឆ្នាំ២០១០ សហចុងចម្លើយឈ្មោះ [redacted] បូរ៉ាក់ និងប្រពន្ធឈ្មោះ [redacted] ឃីម ឬ [redacted] ឃីម បានមកលួងលោងសហដើមចោទ និងប្រជាពលរដ្ឋជាច្រើនអ្នកទៀតឲ្យលេងតុងទីនជាមួយ ដោយក្នុងម្នាក់លេងជាច្រើនក្បាល ហើយការលេងតុងទីននេះដែរ សហចុងចម្លើយជាមេតុងទីន បានដេញមុនគេដោយប្រមូលប្រាក់អស់ ហើយនៅពេលដែលកូនតុងទីនដេញយកវិញ ស្រាប់តែសហចុងចម្លើយមិនបានបើកប្រាក់ឲ្យសហដើមចោទជាកូនតុងទីនឡើយ។ រហូតដល់ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៩ វេលាម៉ោង ២យប់ សហចុងចម្លើយបានលួចរត់គេចខ្លួនបាត់ទៅ ពេលសហដើមចោទជាកូនតុងទីនទាំងអស់បានដឹងដំណឹងពីការរត់គេចខ្លួនរបស់សហចុងចម្លើយ ក៏មានការភ្ញាក់ផ្អើល និងបានប្ដឹងពីសហចុងចម្លើយឈ្មោះ [redacted] បូរ៉ាក់ និងប្រពន្ធឈ្មោះ [redacted] ឃីម ឬ [redacted] ឃីម មកសាលាដំបូងខេត្តកំពង់ស្ពឺ ដោយមានសហដើមចោទឈ្មោះ [redacted] កុលរ៉ាណេ និងឈ្មោះ [redacted] បូរ៉ា ជាអ្នកតំណាងឲ្យកូនតុងទីនចំនួន ៣០នាក់ ហើយទឹកប្រាក់ដែលសហចុងចម្លើយប្រមូលពីសហដើមចោទជាកូនតុងទីនមានទឹកប្រាក់សរុបចំនួន ៦៦៦.៦០០$ (ហុកសិបប្រាំមួយម៉ឺនប្រាំមួយពាន់ប្រាំមួយរយដុល្លារអាមេរិក)។

**-ការអះអាងរបស់សហចុងចម្លើយឈ្មោះកែវ បូរ៉ាក់ និងឈ្មោះ [redacted] ឃីម ឬ [redacted] ឃីម ៖ អវត្តមាន។**

**<u>សំអាងហេតុ</u>**

១.តាមការអះអាងរបស់សហដើមចោទ ឃើញថាមានកាតព្វកិច្ចកើតចេញពីការលេងតុងទីនជាច្រើនខ្សែ រវាងសហដើមចោទ និងសហចុងចម្លើយឈ្មោះ [redacted] បូរ៉ាក់ និងប្រពន្ធឈ្មោះ [redacted] ឃីម ឬ [redacted] ឃីម នៅពេលលេងតុងទីនសហដើមចោទបានប្រគល់ប្រាក់ឲ្យសហចុងចម្លើយចំនួន ៦៦៦.៦០០$ (ហុកសិបប្រាំមួយម៉ឺនប្រាំមួយពាន់ប្រាំមួយរយដុល្លារអាមេរិក) ។ សហដើមចោទបានដេញតុងទីន តែសហចុងចម្លើយមិនបានបើកប្រាក់ឲ្យសហដើមចោទជាកូនតុងទីននោះទេ និងបានរត់គេសខ្លួនបាត់តែម្ដង។

២.តាមការអះអាងរបស់សហដើមចោទបញ្ជាក់ថាចាប់តាំងពីលេងតុងទីនជាមួយសហចុងចម្លើយមក គឺសហចុងចម្លើយបានប្រមូលបានប្រាក់សរុបចំនួន ៦៦៦.៦០០$ (ហុកសិបប្រាំមួយម៉ឺនប្រាំមួយពាន់ប្រាំមួយរយដុល្លារអាមេរិក) ពិតប្រាកដមែន។

៣.តាមបញ្ជីរាមនាម អ្នកប្រវាស់ និងអាស្រ័យផល មានលក្ខណៈគ្រប់គ្រាន់អាចបញ្ជាក់ថា:សហចុងចម្លើយពិតជាមេតុងទីន ហើយសហដើមចោទពិតជាបានលេងតុងទីន និងជំពាក់ប្រាក់សហដើមចោទប្រាកដមែន។

៤.យោងតាមការអះអាង រួមជាមួយនឹងភស្តុតាងជាឯកសារសំអាងរបស់ដើមចោទ មានលក្ខណៈគ្រប់គ្រាន់អាចបញ្ជាក់ថា សហចុងចម្លើយពិតជាមិនបានសងប្រាក់ឲ្យសហដើមចោទក្នុងការលេងតុងទីនសរុបចំនួន ៦៦៦.៦០០$ (ហុកសិបប្រាំមួយម៉ឺនប្រាំមួយពាន់ប្រាំមួយរយដុល្លារអាមេរិក)។

៥.ការទាមទារឲ្យសហចុងចម្លើយឈ្មោះ [redacted] បូរ៉ាក់ និងឈ្មោះ [redacted] ឃីម ឬ [redacted] ឃីម បង់ប្រាក់ជម្ងឺចិត្ត ខាតបង់ពេលវេលា និងសេវាកម្មច្បាប់ចំនួន ៥០.០០០$ (ប្រាំម៉ឺនដុល្លារអាមេរិក) គឺមានចំនួនច្រើនពេកដែលគប្បីតុលាការពិចារណា និងសម្រេចទៅតាមភាពជាក់ស្តែង និងសមហេតុផល។

៦.ការទាមទាររបស់សហដើមចោទត្រង់ចំណុចទី ៣ សហចុងចម្លើយឈ្មោះ [redacted] បូរ៉ាក់ និងឈ្មោះ [redacted] ឃីម ឬ [redacted] ឃីម រឹងរូះមិនព្រមសងបំណុល សុំទាមទាររឹបអូសទ្រព្យសម្បត្តិ(ដី និងផ្ទះ) លក់ឡាយឡុងសងបំណុលមកឲ្យសហដើមចោទឈ្មោះ [redacted] គុលវ៉ាណេ និងឈ្មោះ [redacted] បូរ៉ា គ្រប់ចំនួនគឺជានីតិវិធីអនុវត្តដោយបង្ខំដែលតុលាការមិនគប្បីសម្រេចនៅក្នុងនីតិវិធីបណ្តឹងអង្គសេចក្តីឡើយ ។

៧.ចំពោះការទាមទាររបស់ដើមចោទក្នុងការអនុវត្តសាលក្រមជាបណ្តោះអាសន្ន ពុំមានភាពចាំបាច់ ដែលតម្រូវឲ្យតុលាការធ្វើការអនុវត្តសាលក្រមជាបណ្តោះអាសន្នទេ ។ គប្បីច្រានចោលការទាមទារចំនុចនេះ។

៨.គប្បីឲ្យសហចុងចម្លើយជាអ្នកទទួលបន្ទុកប្រាក់ប្រដាប់ក្តីតាមមាត្រា ៦៤ កថាខណ្ឌ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

## សេចក្តីសម្រេចបញ្ចប់

១.បង្គាប់ឲ្យសហចុងចម្លើយឈ្មោះ [redacted] បូរ៉ាក់ និងឈ្មោះ [redacted] ឃីម ឬ [redacted] ឃីម សងបំណុលចំនួន ៦៦៦.៦០០$ (ហុកសិបប្រាំមួយម៉ឺនប្រាំមួយពាន់ប្រាំមួយរយដុល្លារអាមេរិក) ទៅសហដើមចោទឈ្មោះ [redacted] គុលវ៉ាណេ និងឈ្មោះ [redacted] បូរ៉ា។

២.បង្គាប់ឲ្យសហចុងចម្លើយឈ្មោះ [redacted] បូរ៉ាក់ និងប្រពន្ធឈ្មោះ [redacted] ឃីម ឬ [redacted] ឃីម បង់ប្រាក់ជម្ងឺចិត្ត ខាតបង់ពេលវេលា និងសេវាកម្មច្បាប់ចំនួន ១០.០០០$(មួយម៉ឺនដុល្លារអាមេរិក) ទៅសហដើមចោទឈ្មោះ [redacted] គុលវ៉ាណេ និងឈ្មោះ [redacted] បូរ៉ា។

៣.លើកចោលការទាមទារត្រង់ចំនុចទី ៣ នៃពាក្យបណ្តឹងរបស់សហដើមចោទ។

៤.ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់សហចុងចម្លើយ។

សាលក្រមនេះត្រូវបានប្រកាសនៅសាលសវនាការជាសាធារណៈ នៅថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ ២០២២។ ក្នុងករណីដែលប្តឹងឧទ្ធរណ៍ ត្រូវតែធ្វើឡើងនៅក្នុងរយៈពេល ០១ (មួយ) ខែ គិតចាប់ពីថ្ងៃបានទទួលការបញ្ជូនលិខិតសាលក្រមនេះ។

**ចៅក្រម**

ហត្ថលេខា និងត្រា [redacted]

---

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃសុក្រ ១១កើត ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅខេត្តកំពង់ស្ពឺ ថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២២

បានឃើញ

**ចៅក្រម**

**ក្រឡាបញ្ជី**

[redacted]

[redacted]